ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០៩ ...

ភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង

- ដោយអនុលោមតាមលិខិតលេខ ៧៦២ សជណ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំប្រកាសផ្អាកជាបណ្តោះអាសន្ននូវការចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីព្រៃឈើគ្រប់ប្រភេទ ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមជូនដំណឹងដល់អស់លោក-លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត-ក្រុង ដូចតទៅ :

១- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង ត្រូវផ្អាកការចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅលើដីព្រៃឈើគ្រប់ប្រភេទ ជាពិសេស ដីព្រៃឈើតាមបណ្តោយផ្លូវពីតំបន់កន្ទុយគោ ទៅព្រំប្រទល់ប្រទេសឡាវ ក្នុងខេត្តស្ទឹងត្រែង ។

២- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នឹងចាត់វិធានការយ៉ាងតឹងរឹងបំផុតចំពោះមន្ត្រីណាដែលអនុវត្តផ្ទុយនឹងសេចក្តីជូនដំណឹងនេះ ។

ទទួលបានសេចក្តីជូនដំណឹងនេះ អស់លោក-លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត-ក្រុង ត្រូវខិតខំអនុវត្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីក្រោមឱវាទ ដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ឥម ឈុនលឹម

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ